ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ០៥៦/២១ គ.ជ.

# ជម្រាបជូន

## លោកជំទាវ អគ្គនាយិកា នៃអគ្គនាយកដ្ឋាន ស្ថានីយ៍ វិទ្យុ និងទូរទស្សន៍បាយ័ន

**<u>កម្មវត្ថុ៖</u>** សំណើសុំចាត់អញ្ជើញអ្នកសារព័ត៌មាន ចំនួន ០៣រូប ដើម្បីចូលរួមទទួលព័ត៌មានសម្រាប់ផ្សព្វផ្សាយស្តីពីការសម្រេចរបស់អង្គការសហប្រជាជាតិ ក្នុងការដាក់បញ្ចូលព្រះរាជាណាចក្រកម្ពុជា ក្នុងបញ្ជីនៃ «ប្រទេសជ័យលាភី» ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ (Global Compact for Safe, Orderly and Regular Migration (GCM)) ។

**<u>យោង៖</u>**
- លិខិតលេខ ០៤៤/២១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១
- ចំណារដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២១ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកជំទាវ អគ្គនាយិកា** មេត្តាជ្រាបថា៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នឹងរៀបចំផ្តល់បទសម្ភាសន៍ ដើម្បីផ្សព្វផ្សាយព័ត៌មាន ស្តីពីការសម្រេចរបស់អង្គការសហប្រជាជាតិក្នុងការដាក់បញ្ចូល ព្រះរាជាណាចក្រកម្ពុជា ក្នុងបញ្ជីនៃ «ប្រទេសជ័យលាភី» ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ (Global Compact for Safe, Orderly and Regular Migration (GCM)) ។

កម្មវិធីនឹងប្រារព្ធធ្វើនៅថ្ងៃសុក្រ ១៣កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១៥:០០ នាទីរសៀល នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយអនុវត្តវិធានការណ៍សុខាភិបាល ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **លោកជំទាវ អគ្គនាយិកា** មេត្តាពិនិត្យ និងចាត់អញ្ជើញសមាសភាពតាមការស្នើសុំដើម្បីចូលរួមទទួលព័ត៌មានសម្រាប់ផ្សព្វផ្សាយតាមការគួរ ។

សូម **លោកជំទាវ អគ្គនាយិកា** មេត្តាទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

*ថ្ងៃ ចន្ទ ៩កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០២១*

**ជ.ប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ**
**អនុប្រធានអចិន្ត្រៃយ៍**

ជូ ប៊ុនអេង

*<u>ទូរស័ព្ទទំនាក់ទំនង៖</u>*
*-ឧ.ញ ហាង ជីវ័ន្ត- ០៧៧ ៧០១ ២៣៨*
*-ឧ.ញ ចេង ថ្វី -០១២ ៩៥៨ ២១០*